# ដំណោះស្រាយថាមពលដ៏ជាទីពេញចិត្ត ហើយសន្សំប្រាក់បានច្រើន

*តើលោកអ្នកចំណាយច្រើនបំផុតទៅលើប្រេងឥន្ធនៈ?*

*តើលោកអ្នកកង្វល់ច្រើនជាងគេ ចំពោះប្រេងឥន្ធនៈចេះតែបន្តឡើងថ្លៃ?*

*តើលោកអ្នកមានធនធាន ដែលអាចបម្លែងជាថាមពល ដើម្បីប្រើជំនួសប្រេងឥន្ធនៈ?*




## *យើងមានដំណោះស្រាយ ដ៏ជាទីពេញចិត្តសម្រាប់លោកអ្នក!*



ឡផលិតហ្គាសដោយដុត 'អង្កាម ឬ អុស ស្នូលពោត....'

ក្រុមហ៊ុន **អេសអិមអ៊ី រីញូអេបល អេនើជី លីមីធីត** ផ្តល់នូវដំណោះស្រាយដល់សហគ្រាសរបស់លោកអ្នកអោយអាចសន្សំប្រេង និងបង្កើនការ ផ្គត់ផ្គង់ថាមពលដល់សហគ្រាសរបស់លោកអ្នក។ ដំណោះស្រាយមួយ គឺ ការប្រើឡផលិតហ្គាស ដែលអាចដុត បម្លែង ជីវម៉ាស ដូចជា អង្កាម អុស  ឬ ស្នូលពោត សំបកសណ្តែកដី សំបក ស្វាយចន្ទី អោយក្លាយទៅជាហ្គាស ដែលអាចបញ្ឆេះបាន។ ហ្គាសនេះអាចប្រើជំនួសប្រេងឥន្ធនៈបានរហូតដល់ 60-70ភាគរយ។ ជាមួយនឹងតម្លៃប្រេងបច្ចុប្បន្ន ការប្រើឡផលិតហ្គាស ដើម្បីប្រើជំនួស ប្រេងឥន្ធនៈ ដែលអាចជួយលោកអ្នកអោយសន្សំប្រាក់បានច្រើន។ ចំពោះរោងម៉ាស៊ីនកិនស្រូវ និងសិប្បកម្ម ដែលប្រើប្រេងឥន្ធនៈច្រើន លោកអ្នកអាចប្រើពេលតិចជាង ៣ ឆ្នាំ ដើម្បីស្រង់ដើម។

### ឧទាហរណ៍ឡផលិតហ្គាសសំរាប់ប្រើជាមួយរោងម៉ាស៊ីនកិនស្រូវ

| | |
|---|---|
| ប្រេងដែលត្រូវការប្រើ ពេលបច្ចុប្បន្ន | 3,926 លិត្រក្នុងមួយខែ |
| ចំណាយលើប្រេង ពេលបច្ចុប្បន្ន | 2,473 ដុល្លាក្នុងមួយខែ |
| សមត្ថភាពឡផលិតហ្គាស | 60 kW (គីឡូវ៉ាត់) |
| ចំនួនអង្កាមដែលត្រូវការ | 13 តោនក្នុងមួយខែ |
| ចំនួនប្រេងដែលសន្សំបាន | 2,552 លិត្រក្នុងមួយខែ |
| ប្រាក់ដែលសន្សំបានពីការប្រើហ្គាស | 1,608 ដុល្លាក្នុងមួយខែ |
| រយៈពេលសំរាប់ស្រង់ដើម | 2.4 ឆ្នាំ |

### *តើឡផលិតហ្គាស ផ្តល់ផលប្រយោជន៍អ្វីខ្លះដល់លោកអ្នក?*

- កាត់បន្ថយចំណាយថ្លៃប្រេង
- បម្លែងកាកសំណល់អោយទៅជាថាមពលដែលមានតម្លៃ ដើម្បីប្រើជំនួសប្រេងបាន
- បង្កើនស្ថេរភាពហិរញ្ញវត្ថុ នៃអាជីវកម្មរបស់លោកអ្នក ពីព្រោះលោកអ្នកបន្ថយការពឹងពាក់លើតម្លៃប្រេងឥន្ធនៈ

តម្លៃនៃគំរោងឡផលិតហ្គាស វាអាស្រ័យទៅលើថាមពល ដែលត្រូវការសំរាប់ប្រើ ទំហំម៉ាស៊ីន ថ្លៃទិញជីវម៉ាស (អង្កាម ឬអុស)  និងចំនួនម៉ោង នៃដំណើរការក្នុងមួយឆ្នាំ។ ក្រុមហ៊ុនយើងខ្ញុំអាចផ្តល់ជូន នូវការវាយតម្លៃអោយលោកអ្នកដោយឥតគិតថ្លៃ។

## *សេវាកម្មរួមមាន:*

- ត្រួតពិនិត្យ និងវាយតម្លៃលើប្រព័ន្ធថាមពលបច្ចុប្បន្ន ប៉ាន់ស្មានទំហំថាមពលដែលត្រូវការប្រើ និងចំនួនប្រាក់ដែលអាចសន្សំបាន។
- គូរប្លង់ប្រព័ន្ធឡផលិតហ្គាស ដើម្បីអោយត្រូវនឹងតម្រូវការ និងលក្ខខ័ណ្ឌ។
- ទិញ ដឹកជញ្ជូន និងតម្លើងប្រព័ន្ធឡផលិតហ្គាស រួមទាំងការផ្តល់ការហ្វឹកហ្វឺន អោយចេះប្រើ និងថែទាំប្រព័ន្ធឡផលិតហ្គាស
- គូរប្លង់ និងប្រឹក្សាយោបលបច្ចេកទេសលើប្រព័ន្ធអគ្គិសនី ដើម្បីកាត់បន្ថយការបាត់បង់ និងកាត់បន្ថយចំណាយលើថាមពល
- ប្រឹក្សាយោបលលើការដាំដើមឈើប្រភេទពូជន៍ ដែលធំលូតលាស់ឆាប់ ដើម្បីដុតបម្លែងបង្កើតជាហ្គាសប្រើជំនួសប្រេងឥន្ធនៈ
- ផ្តល់ជូន នូវជំនួយហិរញ្ញវត្ថុ ដែលមានអាត្រាការប្រាក់ថោកសមរម្យ

### គំនូសប្រព័ន្ធឡផលិតហ្គាស និងការផ្តល់ប្រយោជន៍សំរាប់ឧស្សាហកម្មរបស់លោកអ្នក




## *អំពីក្រុមហ៊ុន អេសអិមអ៊ី រីញូអេបល អេនើជី លីមីធិត*

ក្រុមហ៊ុនរបស់យើងខ្ញុំមានអ្នកឯកទេសចំណាន១ យល់ដឹងពីតម្រូវការរបស់កសិឧស្សាហកម្ម និងឧស្សាហកម្មនៅជនបទ។ ក្រុមហ៊ុនយើងខ្ញុំមានបទពិសោធន៍ច្រើនទូលំទូលាយជាមួយនឹងអាជីវកម្មម៉ាស៊ីនកិនស្រូវ ឡឥដ្ឋក្បឿង អគ្គិសនី និងឧស្សាហកម្មផ្សេង១ទៀតនៅជនបទ។ បន្ថែមលើការ ផ្គត់ផ្គង់គ្រឿងបរិក្ខា ក្រុមហ៊ុនយើងខ្ញុំ អាចជួយលោកអ្នកក្នុងការរក នូវដំណោះស្រាយដ៏ប្រសើរបំផុតសំរាប់អាជីវកម្មរបស់លោកអ្នកអោយអាចសន្សំប្រាក់បានច្រើន។ ក្រុមហ៊ុនយើងខ្ញុំផ្គត់ផ្គង់ប្រព័ន្ធឡផលិតហ្គាសដែលមានគុណភាពខ្ពស់ មានការធានា ផ្តល់ការហ្វឹកហ្វឺន ដែលអាចជួយលោកអ្នកសន្សំប្រាក់បានច្រើន។

**ពិតមានបន្ថែម សូមទាក់ទង:**

**ក្រុមហ៊ុន អេសអិមអ៊ី រីញូអេបល អេនើជី លីមីធិត**

អាគារ 92 K ផ្លូវៈសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់2 ខ័ណ្ឌទួលគក ភ្នំពេញ

ទូរស័ព្ទ និងទូរសារ: 023 882 354, 012 834 197, 012 836 229

អ៊ីមែល: seyha@smerenewables.com ឬ danaleuk@yahoo.com

Website: www.smerenewables.com

ក្រុមហ៊ុន អេសអិមអ៊ី រីញូអេបល អេនើជី លីមីធិត បានចុះបញ្ជីស្នាមត្រឹមត្រូវនៅក្រសួងពាណិជ្ជកម្ម